00868726

002/19-09-2007-ECCC/TC
E1/135

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / 12 / 2012
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ សុក្រ ទី ១៩ ខែ តុលា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្ដី- ថ្ងៃទី ១២២

រៀបចំដោយ: ឌុច ផារី និង Matteo CRIPPA

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្ដរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក Matteo CRIPPA, លោកស្រី សែ កុលវុឌ្ឍី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Keith RAYNOR, កញ្ញា សុង ឆវ័ន្ត, លោក វ៉េង ហ៊ត់ |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZZI |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្ដម |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក សំ សុគង់, លោក ឡោ ជុនធី |
| ដើមបណ្ដឹងរដ្ឋប្បវេណី៖ យឹម សុវណ្ណ TCW-169 |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី ស្វ សុទ្ធាវី |
| ផ្សេងៗ៖ កញ្ញា Sonia MESSAOUDI |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ | ចាប់ផ្ដើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.២៥ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.២៥ | បញ្ចប់ម៉ោង៖ ១០.៥៥ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១២.០០ | បញ្ចប់ម៉ោង៖ ១៣.៤៥ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ៤ ម៉ោង និង ៤៥ នាទី | | |

**<u>កិច្ចដំណើរការនីតិវិធី៖</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | ជនជាប់ចោទ អៀង សារី<br>ជនជាប់ចោទ នួន ជា | ៩.០៦<br>១១.៥៩ | ៩.០៧<br>១២.០០ |
| ការដាក់បង្ហាញឯកសារទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាលនិងប្រព័ន្ធទំនាក់ទំនងក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ | មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី<br>មេធាវីការពារក្ដី នួន ជា | ៩.១០<br>១០.៥៦ | ១០.២៥<br>១១.៣០ |
| សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដី ខៀវ សំផន ដែលស្នើសុំប្រើឯកសារ E3/122 | អង្គជំនុំជម្រះ | ៩.៤១ | ៩.៤៤ |
| សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដី នួន ជា ដែលស្នើសុំការបញ្ជាក់ទាក់ទងនឹងនីតិវិធីនៃការដាក់បង្ហាញឯកសារដែលធ្វើឡើងដោយភាគី | អង្គជំនុំជម្រះ | ៩.៤៦ | ៩.៥៤ |

| | | | |
|---|---|---|---|
| សេចក្ដីសម្រេចផ្ទាល់មាត់លើសំណើរបស មេធាវីការពារក្ដី នួន ជា ដែលស្នើសុំដាក់បង្ហាញឯកសារ | អង្គជំនុំជម្រះ | ១០.៥៥<br>១៣.៤៦ | ១២.០០<br>១៣.៤៨ |
| ការព្រមានដល់មេធាវី Ianuzzi ដែលជាមេធាវីការពារក្ដីអន្តរជាតិរបស់លោក នួន ជា | អង្គជំនុំជម្រះ | ១៣.៤៨ | ១៣.៥០ |
| ការស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី យឹម សុវណ្ណ TCW-169 | អង្គជំនុំជម្រះ<br>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី<br>សហព្រះរាជអាជ្ញា | ១៣.៥១<br>១៤.០១<br>១៥.៥១ | ១៣.៥៧<br>១៥.៥០<br>១៦.១៣ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ អៀង សារី (ម៉ោង ៩.០៦) តាមរយៈមេធាវីរបស់គាត់ ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់សម្រាប់រយៈពេលពេញមួយថ្ងៃ ដោយសារមូលហេតុសុខភាព ។ ជនជាប់ចោទ នួន ជា (ម៉ោង ១១.៥៨) តាមរយៈមេធាវីរបស់គាត់ ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់សម្រាប់ពេលរសៀល ។

**ការដាក់បង្ហាញឯកសារទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាលនិងប្រព័ន្ធទំនាក់ទំនងក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ**

មេធាវីនាំមុខតំណាងដើមបណ្ដឹង រដ្ឋប្បវេណីបញ្ចប់ការដាក់បង្ហាញឯកសារ ដែលមេធាវីយល់ថាមានភាពពាក់ព័ន្ធបំផុតទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មក មេធាវីការពារក្ដី នួន ជា ដាក់បញ្ហាញនូវឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទទាំងពីរខាងលើ ចំណែកមេធាវីការពារក្ដី អៀង សារី និង ខៀវ សំផន បានបញ្ជាក់ថា ក្រុមរបស់ខ្លួនមិនមានឯកសារអ្វីត្រូវដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះនោះទេ។

**សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដី ខៀវ សំផន ដែលស្នើសុំប្រើឯកសារ E3/122**

ក្រុមមេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងការប្រើឯកសារ E3/122 ដែលឯកសារនេះមាននូវកំណត់សម្គាល់ដែលបានធ្វើឡើងដោយអ្នកកាសែត ប៉ុន្តែមិនមានការថតសម្លេង ។ អង្គជំនុំជម្រះបដិសេធលើការជម្ទាស់នេះ ដោយបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងពិចារណាអំពីតម្លៃនៃភស្តុតាងចំពោះឯកសារនេះនៅពេលអង្គជំនុំជម្រះចេញសាលក្រម ។

**<u>សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា ដែលស្នើសុំការបញ្ជាក់ផ្ទាល់មាត់នីតិវិធីនៃការដាក់បង្ហាញឯកសារដែលធ្វើឡើងដោយភាគី</u>**

មេធាវីការពារក្តី នួន ជា បានចោទសួរ ថាតើមេធាវីមិនអាចធ្វើការជម្ទាស់ទៅលើអ្វីដែលបានលើកឡើងក្នុងពេលបង្ហាញឯកសារនោះទេ លើកលែងតែកូនក្តីរបស់ខ្លួនមានសំណួរ ឬមានបំណងធ្វើការកត់សម្គាល់ទៅលើឯកសារ ។ អង្គជំនុំជម្រះរំឭកឡើងវិញនូវសេចក្តីសម្រេចរបស់ខ្លួនដែលបានប្រកាសកាលពីថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១២ ទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការធ្វើការកត់សម្គាល់លើឯកសារដែលបានដាក់បង្ហាញដោយភាគី។ ការកត់សម្គាល់នេះអាចធ្វើបានក្រោយពេលភាគីបញ្ចប់នូវការដាក់បង្ហាញឯកសាររបស់ខ្លួន ។

**<u>សេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្តី នួន ជា ដែលស្នើសុំដាក់បង្ហាញឯកសារ</u>**

អង្គជំនុំជម្រះបានបញ្ជាក់ដល់ក្រុមមេធាវីការពារក្តី នួន ជា ថា អង្គជំនុំជម្រះមិនអនុញ្ញាតឱ្យមេធាវីលើកឡើងនូវឯកសារ E119.1.398 និង E3/9 ក្នុងពេលនេះនោះទេ ។ ឯកសារទីមួយដែលបាននិពន្ធដោយអ្នកជំនាញ Philip Short អាចយកមកដេញដោលនៅចំពោះមុខអង្គជំនុំជម្រះបាននៅពេលអ្នកជំនាញនោះមកផ្តល់សក្ខីកម្ម ។ ចំពោះឯកសារទីពីរដែលបាននិពន្ធដោយ Stevphen Heder នោះ អង្គជំនុំជម្រះនឹងសម្រេចនៅពេលក្រោយ ។ ប៉ុន្តែ អង្គជំនុំជម្រះបានបញ្ជាក់ថា ប្រសិនបើអង្គជំនុំជម្រះសម្រេចកោះហៅ Stevphen Heder ដូច្នេះភាគីអាចប្រើឯកសារនោះក្នុងពេលអ្នកជំនាញរូបនេះផ្តល់សក្ខីកម្ម បើមិនដូច្នេះទេ អង្គជំនុំជម្រះនឹងផ្តល់ឱកាសឱ្យភាគីលើកឡើងពីឯកសារនេះនៅពេលក្រោយ ។

បន្ទាប់មកមេធាវីការពារក្តី នួន ជា បានបញ្ជាក់ថា នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាប្រើនូវឯកសារ E3/89 ដែលឯកសារនេះនិពន្ធដោយលោក Stevphen Heder ។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ឯកសារដែលសហព្រះរាជអាជ្ញាបានប្រើគឺ E3/724 និង E3/731 ដែលឯកសារទាំងនោះគឺជាការសង្ខេបនូវទស្សនាវដ្តីទង់បដិវត្តមួយចំនួន ដែលបានរៀបចំដោយ

Stevphen Heder ឬ Ben Kiernan។ អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះមិនមានបំណងកែប្រែនូវសេចក្តីសម្រេចរបស់ខ្លួន ដែលបានសម្រេចពន្យាពេលក្នុងការពិភាក្សាដេញដោលលើឯកសារដែលបាននិពន្ធដោយ Stevphen Heder នោះទេ រហូតទាល់តែអង្គជំនុំជម្រះសម្រេច ថាតើត្រូវកោះហៅអ្នកជំនាញរូបនេះដែរឬទេ ហើយការពន្យាពេលនេះគឺធ្វើឡើងដើម្បីផលប្រយោជន៍រដ្ឋបាលយុត្តិធម៌ ។

**<u>ការព្រមានដល់មេធាវី Ianuzzi ដែលជាមេធាវីការពារក្តីអន្តរជាតិរបស់លោក នួន ជា</u>**

ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីសវនាការនៅពេលព្រឹក លោកមេធាវី Ianuzzi បានធ្វើការកត់សម្គាល់ជាច្រើនលើកច្រើនសា ក្នុងគោលបំណងដើម្បីតវ៉ានិងរិះគន់នូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទាក់ទងនឹងការដឹកនាំកិច្ចដំណើរការនីតិវិធី។ ដោយអាកប្បកិរិយារបស់មេធាវីនេះធ្វើឡើងមិនត្រឹមត្រូវ អង្គជំនុំជម្រះបានព្រមានដល់មេធាវីការពារក្តីថា អនុលោមតាមវិធាន ៣៨ អង្គជំនុំជម្រះអាចហាមឃាត់មិនឱ្យមេធាវីចូលរួមក្នុងកិច្ចដំណើរការសវនាការ ឬចូលរួមនៅទីកន្លែងបម្រុងទុកសម្រាប់សាធារណៈជន ។

**<u>ការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណា TCW-169</u>**

អង្គជំនុំជម្រះបានចាប់ផ្តើមតាំងសំណួរបឋមមួយចំនួនដល់ដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់មកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាតាំងសំណួរដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ មេធាវីការពារក្តីទាំងបីក្រុមបញ្ជាក់ថា ក្រុមរបស់ខ្លួនមិនមានសំណួរដែលត្រូវចោទសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| TC Ref Number | OCIJ Ref Number | Name/Description | Party/TC | Remarks (ERN) |
|---|---|---|---|---|
| E109/2.3 | | Video Survive in the heart of the Khmer rouge madness | CPLCL | 1mn 30s. to 28mn 20s. |
| IS 9.1 | | លក្ខន្តិកៈបក្សកុម្មុយនីសកម្ពុជា | CPLCL | 00184038-45 (EN)<br>00053025-33 (KH) |
| E3/18 | | សៀវភៅនិពន្ធដោយ ខៀវ សំផន មានចំណងជើងថា៖ "ប្រវត្តិសាស្ត្រកម្ពុជា ថ្មីៗ | CPLCL | 00103785 (EN)<br>00103883 (KH)<br>00598497 (FR) |

| | | | | |
|---|---|---|---|---|
| | | នេះនិងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់" | | |
| E3/122 | | ឯកសារភ្ជាប់ ៨១៖ បទសម្ភាសន៍របស់ អៀ ម៉េងទ្រី និង សូក្រ័ក្ត លឿង ជាមួយ ខៀវ សំផន ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០០៦ | CPLCL | 00000926 (EN)<br>00613201 (FR)<br>00347033 (KH)<br><br>00000929-30 (EN)<br>00613204-05 (FR)<br>00347037-39 (KH)<br><br>00000932 (EN)<br>00613208 (FR)<br>00347042-43 (KH)<br><br>00000933 (EN)<br>00613210 (FR)<br>00347046 (KH) |
| E3/204 | | កិច្ចសម្ភាសន៍របស់ VOA ជាមួយ ខៀវ សំផន (14/11/2007) | CPLCL | 00680033-34 (EN)<br>00424211-12 (KH)<br>00656178-79 (FR) |
| | D22/289 | ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លោក ចៅ ឃឹម | CPLCL | 00490612-18 (EN)<br>00478700-708 (KH)<br>00794408-16 (FR) |
| | D22/289.21 | Annexe 21: Interview de CHAU Seng au nom du Front Uni National du Kampuchea | CPLCL | |
| | D22/289.11 | ឧបសម្ព័ន្ធ ១១៖ ចៅ សេង សរសេរ ទៅភរិយានៅបារាំង ពីប៉េកាំង | CPLCL | 00806052 (EN)<br>00797532-33 (KH)<br>00481462-63 (FR) |
| | D22/289.14 | ឧបសម្ព័ន្ធ ១៤៖ បញ្ជីឈ្មោះអ្នកធ្វើមាតុភូមិនិវត្តពីបរទេសមកកាន់កម្ពុជាប្រជាធិបតេយ្យចន្លោះឆ្នាំ ១៩៧៥ ទៅឆ្នាំ | CPLCL | 00481501-18 (EN)<br>00788312-39 (KH) |

| | | | | |
|---|---|---|---|---|
| | | ១៩៧៦ | | |
| | D22/44 | ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់លោកស្រី LEFEUVRE Martine | CPLCL | |
| | D22/44.1 1 | ឧបសម្ព័ន្ធ ១១: សំបុត្រទូតកម្ពុជាប្រចាំប្រទេសចិនអោយ អ៊ុក កេត ត្រលប់មកកម្ពុជា | CPLCL | 00326564 (EN)<br>00281227 (KH)<br>00338993 (FR) |
| | D22/44.1 3 | ឧបសម្ព័ន្ធ ១៣៖ បញ្ជីឈ្មោះអ្នកទោសកំទេចថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ៧៧ | CPLCL | 00328268 (EN)<br>00339169 (FR)<br>00281230 (KH) |
| | D22/289. 17 | Annexe 17: Liste des "Khmers de l'étranger" tués à Tuol Sleng entre Avril 1975 et Janvier 1979 | CPLCL | |
| E3/200 | | សន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគំរប់ខួប នៅថ្ងៃទី ១៥ មេសា១៩៧៧ | CPLCL | S 00004164 (EN)<br>00292804 (KH)<br>00612165 (FR) |
| E3/1568 | | អត្ថបទដែលបានវាយសារឡើងវិញពីអត្ថបទសរសេរដោយដៃនៃបទសម្ភាសន៍ជាមួយ ជា ស៊ីម ថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ១៩៩១ និង ហេង សំរិន ២ ខែធ្នូ ឆ្នាំ ១៩៩១ នៅទីក្រុង ភ្នំពេញ | NC Defense | 00651878-80 (EN)<br>00713945-48 (KH)<br>00743349-51 (FR)<br><br>00651884 (EN)<br>00713955 (KH)<br>00743356 (FR) |
| | D246/4 | កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី YIM Sovann យឹម សុវណ្ណ | CPLCL<br><br>OCP | 00379313 (EN)<br>00485887 (FR)<br>00373424 (KH)<br><br>00379315 (EN)<br>00485889 (FR)<br>00373426 (KH) |
| E163/5 | | អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការ | NC Defense | |

| | | | | |
|---|---|---|---|---|
| | | ជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារE163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន | | |

| ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖ |
|---|
| • អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការសម្រាប់ពេលរសៀល និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។ |
| • បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩.០០ ព្រឹក ថ្ងៃច័ន្ទ ទី ២២ ខែ តុលា ឆ្នាំ ២០១២។ |

| កាលបរិច្ឆេទបន្តសវនាការ៖ |
|---|
| សវនាការនឹងបន្តនៅថ្ងៃ ច័ន្ទ ទី ២២ ខែ តុលា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

ឌុច ផារ៉ា Matteo CRIPPA